ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០៣៣ អក
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ: ៧៨ (ណ)
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣

# តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាលបានបើកសវនាការនៅសាលាសវនាការ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

## តំណាងអយ្យការ

លោក **ហោ លីណា** ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

## មេធាវីការពារក្តី

លោក [redacted] ជាមេធាវីការពារក្តីឱ្យជនត្រូវចោទឈ្មោះ វ៉ាន់ឌី ចន្ទ្រា

លោក [redacted] ,លោក [redacted] ជា មេធាវីការពារក្តីឱ្យជនត្រូវចោទឈ្មោះ [redacted] ចាន់នឿន

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៣៣ អ.ក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] **ចាន់នឿន** ភេទប្រុស អាយុ៤៤ឆ្នាំ (អាយុពេលកើតហេតុ) ជនជាតិ ខ្មែរ មុខរបរមន្ត្រីរាជការ ទីកន្លែងកំណើតភូមិ[redacted] ខេត្ត កណ្ដាល និងទីលំនៅបច្ចុប្បន្ននៅក្រោយគោល សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានី ភ្នំពេញ ឪពុកឈ្មោះ [redacted] សឿន (ស) ម្ដាយឈ្មោះ [redacted] ប៉ិច (ស) ប្រពន្ធឈ្មោះ [redacted] សុខា មានកូនចំនួន ០៣ នាក់ ជានីតិជន ទោសពីមុខគ្មាន (ក្រៅឃុំ)

២.ឈ្មោះ [redacted] ចន្ទ្រា ភេទប្រុស អាយុ២៩ឆ្នាំ (អាយុពេលកើតហេតុ) ជនជាតិខ្មែរ មុខរបរបើកបររថយន្ត ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកោះកុង ឪពុកឈ្មោះ [redacted] វ៉ាន់ឌី (ស) ម្ដាយឈ្មោះ [redacted] ធា (ស) ប្រពន្ធឈ្មោះ [redacted] ថា មានកូនចំនួន ០២ នាក់ ជានីតិជន ទោសពីមុខគ្មាន (ក្រៅឃុំ)។

ចោទពីបទ: **បើកបរដោយធ្វេសប្រហែស មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដល់ទៃ** ព្រឹត្តនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

*អង្គហេតុនៃរឿងមានដូចតទៅ៖*

មុនពេលកើតហេតុ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៨ និង ១៥ នាទី មានរថយន្តមួយគ្រឿងម៉ាក TOVOTA PRIUS ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ ២BG-២៧៤៦ បើកបរដោយឈ្មោះ [redacted] ចាន់នឿន ភេទប្រុស អាយុ៤៤ឆ្នាំ និងមានអ្នករួមដំណើរចំនួន ០៤ នាក់ បើកបរមានទិសដៅពីជើង

ទៅត្បូង (ខមុង-ភ្នំពេញ) លុះពេលបើកបរមកដល់ ចន្លោះផ្លូវជាតិលេខ៥ ចន្លោះគីឡូម៉ែត្រ ២៧-២៨ ដែលស្ថិតនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ក៏បានរ៉ារថយន្តមួយគ្រឿងម៉ាក SCANIA ពណ៌ទឹកក្រូច ពាក់ផ្លាកលេខ ស្វាយរៀង ៣A-៤៦៧៧ មានសណ្តោងរ៉ឺម៉ក ពាក់ផ្លាកលេខភ្នំពេញ ៤A-៩១៧៧ បើកបរដោយឈ្មោះ វ៉ាន់ឌី ចន្ទ្រា ភេទប្រុស អាយុ២៩ឆ្នាំ ដែលបើកបរនៅខាងមុខ(បើកបរមានទិសដៅស្របគ្នា) ហើយរថយន្តម៉ាក TOVOTA PRIUS បានបើកងាកមកខាងឆ្វេងចូលពីមុខរថយន្តម៉ាក SCANIA ដោយសារប្រកៀកគ្នាពេក ក៏ត្រូវរថយន្តម៉ាក SCANIA បុកពីក្រោយ ចំហៀងផ្នែកខាងឆ្វេងរថយន្តម៉ាក TOVOTA PRIUS ហើយរថយន្តម៉ាក TOVOTA PRIUS បានរ៉េចង្កូតឡើងទៅលើស្ទួនពុះចែកទ្រូវផ្លូវ ហើយទៅបុកបង្គោលផ្លាកសញ្ញាដែលនៅលើស្ទួន ពុះចែកទ្រូងផ្លូវនោះ ធ្វើឱ្យមានអ្នករបួស និងខូចខាតរថយន្តទាំង ០២ គ្រឿងខាងលើតែម្តង។

-បានឃើញ ដីកាដំណោះស្រាយលេខ: ៤៦៩ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះបន្តលេខ: ២៦៦ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

-អានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់នឿន បានឆ្លើយថា៖ ខ្លួននៅតែប្តឹងទៅលើអ្នកបើកបររថយន្តធន់ធ្ងន់ ពាក់ស្លាកលេខ ស្វាយរៀង 3A- 5677 ដែលបានបង្ករគ្រោះថ្នាក់ចរាចរណ៍មកលើរថយន្តរបស់ខ្លួននៅចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១។ នៅថ្ងៃកើតហេតុខ្លួនបានបើកបរ រថយន្តម៉ាកព្រូស ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2BG-2746 ពីស្រុកពញាឮឆ្ពោះមករាជធានីភ្នំពេញ លុះមកដល់ចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល នៅពេលនោះខ្លួនបានឃើញ រថយន្តធន់ធំបើកបរនៅគន្លងផ្លូវល្បឿនលឿន ពេលនោះខ្លួនក៏បានស៊ីផ្លេស៊ុំវ៉ា ដោយវានៅខាងស្តាំរថយន្តធន់ធំ ហើយពេលនោះខ្លួនបានបើករថយន្តវាផុតរថយន្តធន់ធំនោះ ហើយខ្លួនបានបើកចូលទៅគន្លងខាងឆ្វេងវិញ ហើយបើកបរធម្មតាទៅមុខបានមួយសន្ទុះ ក៏មានរថយន្តដែលបើកបរនៅខាងមុខរថយន្តខ្លួនបានបន្ថយល្បឿន នៅពេលនោះខ្លួនក៏បានបន្ថយល្បឿនរថយន្តរបស់ខ្លួន ក៏ស្រាប់តែរថយន្តធន់ធំនោះ បានមកបុករថយន្តខ្លួនពីក្រោយ ធ្វើឱ្យរថយន្តរបស់ខ្លួនខ្ទាតទៅបុកជាមួយនឹងស្ទួនច្បារ ហើយក្រឡាប់ទៅបុកជាមួយបង្គោលប៉ាណូផ្សាយពាណិជ្ជកម្ម ហើយនៅពេលនោះ កូនរបស់ខ្លួនបានចេញពីក្នុងរថយន្ត មកលើស្ទួនច្បារ ចំណែកមនុស្សបួននាក់ទៀតនៅក្នុងរថយន្ត។ ចំណែកអ្នកជិះនៅក្នុងរថយន្តរបស់ខ្លួន មានរបួសចំនួន០៥នាក់ ហើយក៏ត្រូវបងប្អូនដឹកបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យ។ នៅពេលបើកបរ គឺខ្លួនមានប័ណ្ណបើកបររថយន្តត្រឹមត្រូវ ហើយខ្លួនមិនបានផឹកគ្រឿងស្រវឹងនោះទេ ហើយនៅពេលជួប គ្រោះថ្នាក់ចរាចរណ៍នោះ គឺខ្លួនបានបើកបរក្នុងល្បឿនប្រហែល ៤០ ទៅ ៥០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

-អានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចន្ទ្រា បានឆ្លើយថា៖ ខ្លួនជាអ្នកបើកបររថយន្តឱ្យថៅកែឈ្មោះ [redacted]រ៉ាមបូ ភេទប្រុស អាយុ ៣០ ឆ្នាំ ដែលមានទីលំនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ នៅថ្ងៃកើតហេតុ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៦ ល្ងាច ខ្លួនបានបើកបររថយន្តម៉ាក SCANIA ពណ៌ទឹកក្រូច ពាក់ផ្លាកលេខ ស្វាយរៀង 3A-5677 សណ្តោងរ៉ឺម៉ក ពាក់ផ្លាកលេខ 4A-9177 ចេញពីខេត្តកំពង់ឆ្នាំង ឆ្ពោះមករាជធានីភ្នំពេញ លុះពេលបើកបរមកដល់ចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ក៏បានជួបគ្រោះថ្នាក់ចរាចរណ៍ ជាមួយរថយន្តមួយគ្រឿងម៉ាក PRIUS ដោយរថយន្ត PRIUS នោះបានបើកវាខាងស្តាំរថយន្តរបស់ខ្លួន ហើយបានវាជិតផុតរថយន្តរបស់ខ្លួន ក៏ឃើញមានរថយន្តមួយទៀតនៅពីខាងមុខនៅ ពេលនោះស្រាប់តែរថយន្តម៉ាក PRIUS នោះ បានបត់ចូលមកខាងមុខរថយន្តរបស់ខ្លួនដែលកំពុងបើកបណ្តាល ឱ្យប៉ះចំចង្កៀងស៊ីញ៉ូខាងស្តាំ ហើយរថយន្តនោះបោកវិលមកខាង



Scanned with CamScanner

ឆ្វេង ទៅបុកជាមួយគំនូសចែកទ្រូងផ្លូវ ហើយហោះទៅផ្លូវម្ខាងទៀត។ ក្រោយពេលប៉ះគ្នាជាមួយរថយន្តម៉ាក PRIUS នោះខ្លួនបាន ឈប់រថយន្តនៅកន្លែងកើតហេតុ ហើយក៏បានចុះពីរថយន្តគេចចេញពីកន្លែងកើតហេតុ។ នៅពេលមានគ្រោះថ្នាក់នោះ ខ្លួនបានឃើញខាងភាគីរថយន្ត PRIUS មានរបួស ០៤ ទៅ ០៥ នាក់។ នៅពេលបើកបររថយន្តនោះ គឺខ្លួនបើកបរក្នុងល្បឿនប្រហែល ២០ ទៅ ៣០ គីឡូ ម៉ែត្រក្នុងមួយម៉ោងហើយខ្លួនមិនបានផឹកគ្រឿងស្រវឹងនោះទេ ហើយខ្លួនមានប័ណ្ណបើកបររថយន្តត្រឹមត្រូវ។ នៅពេលបើកបរនោះ គឺ រថយន្តរបស់ខ្លួនពុំបានទៅបុករថយន្ត PRIUS នោះទេ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចន្ទ្រា បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ខាងលើនេះគឺ មិនមែនកើតចេញពីការបើកបរធ្វេសប្រហែស របស់កូនប្តីខ្លួននោះទេ ដោយហេតុថាក្នុង អំឡុងពេលបើកបរកូនក្តីខ្លួនបានបើកបរតាមល្បឿនច្បាប់កំណត់ ហើយជាក់ស្តែងកូនក្តីរបស់ខ្លួនក៏ជាអ្នកប្រកបអាជីពបើកបររថយន្តដែលមានបទពិសោធន៍ច្រើនឆ្នាំ និងមានប័ណ្ណបើកបរត្រឹមត្រូវផងដែរ។ ការណ៍នេះ អាចបញ្ជាក់ បានថា មុនពេលកើតហេតុនោះ កូនក្តីរបស់ខ្លួន គឺពិតជាបានបើកបររថយន្តក្រោមស្មារតីនឹងនរ និងទំនួលខុសត្រូវបំផុតពិតប្រាកដមែន។ លើសពីនេះទៅទៀតបើយោងតាមរបាយការណ៍សរុបនៃសំណុំរឿងលេខ ០០២ រ.ប.ក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ផែនការសណ្តាប់ធ្នាប់ ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនោះ ករណីគ្រោះថ្នាក់ចរាចរណ៍ខាងលើនេះ គឺកើតឡើងដោយសារមូលហេតុសំខាន់តែមួយប៉ុណ្ណោះ ពោលគឺកើតចេញពីការបើកបរខ្ជីខ្ជាធ្វេសប្រហែស និងខ្វះការប្រុងប្រយ័ត្ន តាមរយៈការបើកបរជែងក្នុងស្ថានភាពគ្រោះថ្នាក់ របស់ឈ្មោះ [redacted] ចាន់ធឿន ដែលជាម្ចាស់របស់រថយន្ត TOYOYA PRIUS នោះទេ ។ ប្រសិនបើ ម្ចាស់រថយន្តម៉ាក TOYOTA PRIOUS ខាងលើនេះ មិនបានធ្វើការបើកវ៉ាជែងខាងស្តាំរថយន្តរបស់កូនក្តីខ្លួនដោយគ្មានការប្រុងប្រយ័ត្ន និងងាកចង្កូតខាងឆ្វេងចូលពីមុខរថយន្តរបស់កូនក្តី ខ្លួនដោយភាពតក់ក្រហល់ និងប្រកិតប្រកៀកពេកទេ នោះគ្រោះថ្នាក់ចរាចរណ៍ខាងលើនេះ ក៏មិនអាចកើតឡើងផងដែរ។ ផ្ទុយទៅវិញ នៅក្នុងដំណាក់កាលស៊ើបសួរក៏ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា កូនក្តីរបស់ខ្លួនបាន បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា ឬមិនប្រុងប្រយ័ត្ននោះឡើយ ពោលគឺមានតែការសន្និដ្ឋានចោទប្រកាន់របស់តំណាងអយ្យការ ដោយពុំមានភស្តុងនោះឡើយ គឺមានតែវិមតិសង្ស័យតែប៉ុណ្ណោះ ជាគោលការណ៍វិមតិសង្ស័យនេះ ត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ។ សរុបរួមមកកូនក្តីខ្លួនពុំបានប្រព្រឹត្តនូវ បទបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យមានរបួសដល់អ្នកដទៃ ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ ហេតុនេះក្នុងនាម ខ្លួនជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ចន្ទ្រា ដែលជាជនជាប់ចោទនៃបទល្មើសខាងលើ សូមសំណូមពរដល់លោកចៅក្រម សម្រេចឱ្យកូនក្តីរបស់ខ្លួនឱ្យរួចផុតពីបទចោទប្រកាន់ចំពោះ "បទបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យមានរបួសដល់អ្នកដទៃ" នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ០៣៣ អ.ក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល តាមនីតិវិធីច្បាប់។

-មេធាវីរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នឿន បានធ្វើសេចក្តីសន្និដ្ឋានថា: នៅពេលកើតហេតុរថយន្តរបស់កូនក្តីខ្លួន ត្រូវរថយន្តធំបុកពីក្រោយបណ្តាលឲ្យក្រឡាប់ និងមានមនុស្សរងគ្រោះចំនួន ៥នាក់ ទី១. ឈ្មោះ [redacted] ចាន់នឿន រងរបួសធ្ងន់, ទី២. ឈ្មោះ [redacted] ស៊ី ណាស៊ែល (កូន) រងរបួសធ្ងន់, ទី៣. ឈ្មោះ [redacted] សុផា (ប្រពន្ធ) រងរបួសស្រាល , ទី៤. ឈ្មោះ [redacted] ណាន់ស៊ី (កូន) រងរបួសស្រាល និងឈ្មោះ [redacted] ស៊ីអេ (កូន) រងរបួសស្រាល។ ក្រោយពេលកើតហេតុ កូនក្តីខ្លួនត្រូវបានសាច់ញាតិ បញ្ជូនទៅមន្ទីពេទ្យដើម្បីព្យាបាល ដូច្នេះនៅពេលមន្ត្រីប៉ូលីសចរាចរណ៍ ធ្វើការវាស់វែង និងធ្វើគំរោងដើមនៃគ្រោះថ្នាក់ចរាចរណ៍មិនមានអ្នកណានៅឈចង្អុលបង្ហាញទេ គឺមន្ត្រីប៉ូលីសចរាចរណ៍ ធ្វើគំនូសស្នាមនៃគ្រោះថ្នាក់ចរាចរណ៍ តាមតែការចង្អុលបង្ហាញរបស់ភាគីតែម្ខាងប៉ុណ្ណោះ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ។ ហេតុនេះក្នុងនាម ខ្លួនជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ ណាម ចាន់នឿន ដែលជាជនជាប់ចោទនៃ

បទល្មើសខាងលើ សូមសំណូមពរដល់ លោកចៅក្រម សម្រេចឱ្យកូនក្តីរបស់ខ្លួនឱ្យរួចផុតពីបទចោទប្រកាន់ ចំពោះ "បទបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យមានរបួសដល់អ្នកដទៃ" និងសុំទាមទារសំណងជម្ងឺចិត្តនឹងការខូចខាតជាប្រាក់ចំនួន USD ២០.០០០ (ពីរម៉ឺនដុល្លារអាមេរិក) និងសេវាកម្មមេធាវី USD ៥.០០០ (ប្រាំពាន់ដុល្លារអាមេរិក)។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ មានភស្តុតាង និងពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] ចាន់នឿន និងឈ្មោះ [redacted] ចន្ទ្រា ជាប់ចោទពីបទៈ **បើកបរដោយធ្វេសប្រហែស មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដល់ទៃ** ប្រព្រឹត្តនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

*ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

**យល់ឃើញថា៖**

**ក.អំពីពិរុទ្ធភាព**

១-តាមដីកាដំណោះស្រាយលេខ: ៧៤៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ពីបទ **បើកបរដោយធ្វេសប្រហែស មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដល់ទៃ** ព្រឹត្តនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ចាន់នឿន** បានឆ្លើយថា៖ ខ្លួននៅតែប្តឹងទៅលើអ្នកបើកបររថយន្តធុនធ្ងន់ ពាក់ស្លាកលេខ ស្វាយរៀង 3A- 5677 ដែលបានបង្ករគ្រោះថ្នាក់ចរាចរណ៍មកលើរថយន្តរបស់ខ្លួននៅចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១។ នៅថ្ងៃកើតហេតុខ្លួនបានបើកបរ រថយន្តម៉ាកព្រូស ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2BG-2746 ពីស្រុកពញាឮ ឆ្ពោះមករាជធានីភ្នំពេញ លុះមកដល់ចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល នៅពេលនោះខ្លួនបានឃើញ រថយន្តធុនធំបើកបរនៅគន្លងផ្លូវល្បឿនលឿន ពេលនោះខ្លួនក៏បានស៊ីផ្លេស៊ុំវ៉ា ដោយវានៅខាងស្តាំរថយន្តធុនធំ ហើយពេលនោះខ្លួនបានបើករថយន្តវ៉ាផុតរថយន្តធុនធំនោះ ហើយខ្លួនបានបើកចូលទៅគន្លងខាងឆ្វេងវិញ ហើយបើកបរធម្មតាទៅមុខបានមួយសន្ទុះ ក៏មានរថយន្តដែលបើកបរនៅខាងមុខរថយន្តខ្លួនបានបន្ថយល្បឿន នៅពេលនោះខ្លួនក៏បានបន្ថយល្បឿនរថយន្តរបស់ខ្លួន ក៏ស្រាប់តែរថយន្តធុនធំនោះ បានមកបុករថយន្តខ្លួនពីក្រោយ ធ្វើឱ្យរថយន្តរបស់ខ្លួនខ្ទាតទៅបុកជាមួយនឹងសួនច្បារ ហើយក្រឡាប់ទៅបុកជាមួយបង្គោលប៉ាណូផ្សាយពាណិជ្ជកម្ម ហើយនៅពេលនោះ កូនរបស់ខ្លួនបានចេញពីក្នុងរថយន្ត មកលើសួនច្បារ ចំណែកមនុស្សប្អូននាក់ទៀតនៅក្នុងរថយន្ត។ ចំណែកអ្នកជិះនៅក្នុងរថយន្តរបស់ខ្លួន មានរបួសចំនួន០៥នាក់ ហើយក៏ត្រូវបងប្អូនដឹកបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យ។ នៅពេលបើកបរ គឺខ្លួនមានប័ណ្ណបើកបររថយន្តត្រឹមត្រូវ ហើយខ្លួនមិនបានផឹកគ្រឿងស្រវឹងនោះទេ ហើយនៅពេលជួប គ្រោះថ្នាក់ចរាចរណ៍នោះ គឺខ្លួនបានបើកបរក្នុងល្បឿនប្រហែល ៤០ ទៅ ៥០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ចន្ទ្រា បានឆ្លើយថា៖ ខ្លួនជាអ្នកបើកបររថយន្តឱ្យថៅកែឈ្មោះ [redacted] វ៉ាមបូ ភេទប្រុស អាយុ ៣០ ឆ្នាំ ដែលមានទីលំនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ នៅថ្ងៃកើតហេតុ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៦ ល្ងាច ខ្លួនបានបើកបររថយន្តម៉ាក SCANIA ពណ៌ទឹកក្រូច ពាក់ផ្លាកលេខ ស្វាយរៀង 3A-5677 សណ្តោងរ៉ឺម៉ក ពាក់ផ្លាកលេខ 4A-9177 ចេញពីខេត្តកំពង់ឆ្នាំង ឆ្ពោះមករាជធានីភ្នំពេញ លុះពេលបើកបរមកដល់ចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ក៏បានជួបគ្រោះថ្នាក់ចរាចរណ៍ ជាមួយរថយន្តមួយគ្រឿងម៉ាក PRIUS ដោយរថយន្ត PRIUS នោះបានបើកវ៉ាខាងស្តាំរថយន្តរបស់ខ្លួន ហើយបានវ៉ាជិតផុតរថយន្តរបស់ខ្លួន ក៏ឃើញមានរថយន្តមួយទៀតនៅពីខាងមុខនៅ ពេលនោះស្រាប់តែរថយន្តម៉ាក PRIUS នោះ បានបត់ចូលមកខាងមុខ



Scanned with CamScanner

រថយន្តរបស់ខ្លួនដែលកំពុងបើកបណ្តាល ឱ្យប៉ះចំចង្កៀងស៊ីញ៉ូខាងស្តាំ ហើយរថយន្តនោះបោករវិលមកខាងឆ្វេង ទៅបុកជាមួយគំនូសចែកទ្រូងផ្លូវ ហើយហោះទៅផ្លូវម្ខាងទៀត។ ក្រោយពេលប៉ះគ្នាជាមួយរថយន្តម៉ាក PRIUS នោះខ្លួនបាន ឈប់រថយន្តនៅកន្លែងកើតហេតុ ហើយក៏បានចុះពីរថយន្តគេចចេញពីកន្លែងកើតហេតុ។ នៅពេលមានគ្រោះថ្នាក់នោះ ខ្លួនបានឃើញខាងភាគីរថយន្ត PRIUS មានរបួស ០៤ ទៅ ០៥ នាក់។ នៅពេលបើកបររថយន្តនោះ គឺខ្លួនបើកបរក្នុងល្បឿនប្រហែល ២០ ទៅ ៣០ គីឡូ ម៉ែត្រក្នុងមួយម៉ោងហើយខ្លួនមិនបានផឹកគ្រឿងស្រវឹងនោះទេ ហើយខ្លួនមានប័ណ្ណបើកបររថយន្តត្រឹមត្រូវ។ នៅពេលបើកបរនោះ គឺ រថយន្តរបស់ខ្លួនពុំបានទៅបុករថយន្ត PRIUS នោះទេ។

៤-តាមរបាយការណ៍បូកសរុបលេខៈ ០០២ រ.ប.ក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ របស់នាយការិយាល័យជាមន្ត្រីនគរបាលយុត្តិធម៌ អង្គភាពការិយាល័យផ្លូវគោក នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានធ្វើសេចក្តីផ្ទានថាៈ ករណីនេះបណ្តាលមកពី អ្នកបើកបររថយន្តម៉ាក TOYOTA PRIUS បើកបរខ្ចីខ្ចាខ្វះការប្រុងប្រយ័ត្ន ប្រជែងក្នុងស្ថានភាពគ្រោះថ្នាក់ និងអ្នកបើកបររថយន្តម៉ាក SCANIA ឧបសគ្គខាងមុខកៀកពេក មិនអាចគេចផុតពីគ្រោះថ្នាក់បាន។

៥-ផ្អែកតាមចម្លើយជនជាប់ចោទ និងភស្តុតាងផ្សេងៗ ពិតជាមានរថយន្ត មួយគ្រឿងម៉ាក TOVOTA PRIUS ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ ២BG-២៧៤៦ បើកបរដោយឈ្មោះ [redacted] ចាន់នឿន ភេទប្រុស អាយុ៤៤ឆ្នាំ និងមានអ្នករួមដំណើរចំនួន ០៤ នាក់ បើកបរមានទិសដៅពីជើង ទៅត្បូង (ឧដុង-ភ្នំពេញ) លុះពេលបើកបរមកដល់ ចន្លោះផ្លូវជាតិលេខ៥ ចន្លោះគីឡូម៉ែត្រ ២៧-២៨ ដែលស្ថិតនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ក៏បានវ៉ារថយន្តមួយគ្រឿងម៉ាក SCANIA ពណ៌ទឹកក្រូច ពាក់ផ្លាកលេខស្វាយរៀង ៣A-៤៦៧៧ មានសណ្តោងរ៉ឺម៉ក ពាក់ផ្លាកលេខភ្នំពេញ ៤A-៩១៧៧ បើកបរដោយឈ្មោះ [redacted] ចន្ទ្រា ភេទប្រុស អាយុ២៩ឆ្នាំ ដែលបើកបរនៅខាងមុខ(បើកបរមានទិសដៅស្របគ្នា) ហើយរថយន្តម៉ាក TOVOTA PRIUS បានបើកងាកមកខាងឆ្វេងចូលពីមុខរថយន្តម៉ាក SCANIA ដោយ សារប្រកៀកគ្នាពេក ក៏ត្រូវរថយន្តម៉ាក SCANIA បុកពីក្រោយចំហៀងផ្នែកខាងឆ្វេងរថយន្តម៉ាក TOVOTA PRIUS ហើយរថយន្តម៉ាក TOVOTA PRIUS បានរ៉េចង្កូតឡើងទៅលើស្ទួនពុះចែកទ្រូវផ្លូវ ហើយទៅបុកបង្គោលផ្លាកសញ្ញាដែលនៅលើស្ទួន ពុះបែកទ្រូងផ្លូវនោះ ធ្វើឱ្យមានអ្នករបួស និងខូចខាតរថយន្តទាំង ០២ គ្រឿងខាងលើ តែម្តងពិតប្រាកដមែន។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់នឿន** និងឈ្មោះ [redacted]ចន្ទ្រា ស៊ីណាត មានចេតនាទុច្ចរិត **ធ្វើឱ្យខូចខាតដោយចេតនា និងបង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកក្មេង ឃុំព្រែកក្មេង ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ តាមមាត្រា ៥២ និងមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៧-អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានធាតុផ្សំគ្រប់គ្រាន់ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីការចរាចរណ៍ផ្លូវគោក។

៨-ជនជាប់ចោទឈ្មោះ [redacted]**ចាន់នឿន** និងឈ្មោះ[redacted] ចន្ទ្រា ជាសមត្ថជន ស្មារតីធម្មតា អាចយល់ដឹងពីបច្ច័យ និងព្យសនកម្ម ដែលកើតឡើងពីអំពើរបស់ខ្លួន ដែល បានប្រព្រឹត្ត។

៩-មានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់ពីពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] **ចាន់នឿន** និងឈ្មោះ [redacted] ចន្ទ្រា (មានសារធាតុជាតិគ្រប់គ្រាន់ដូចខាងលើ) ពីបទ **បើកបរដោយធ្វេសប្រហែស មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដល់ទៃ** ព្រឹត្តនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**ខ-អំពីសំណង** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់នឿន បានទាមទារថ្លៃព្យាបាលចំនួន USD ៨.០០០ (ប្រាំបីពាន់ដុល្លារអាមេរិក) និងថ្លៃខូចខាតរថយន្តចំនួន USD ១៤.០០០ (មួយម៉ឺនបួនពាន់ដុល្លារ

មេរិក) តុលាការយល់ឃើញថា ពុំមានភស្តុតាងដែលបញ្ជាក់អំពីតម្លៃ និងការខូតខាតច្បាស់លាស់នោះទេ ម្យ៉ាងវិញទៀត ម្ចាស់រយន្តម៉ាក TOYOTA PRIUS ក៏ជាអ្នកបើកបរខ្វះខ្វាះការប្រុងប្រយ័ត្ន ប្រជែងក្នុងស្ថានភាពគ្រោះថ្នាក់ ដូច្នេះអាចឱ្យតុលាការពិនិត្យ និងពិចារណាអំពីសំណងតាមភាពជាក់ស្តែង។

**ខ-អំទោស៖**

**ហេតុដូច្នេះ តុលាការ**

**<u>សម្រេច</u>**

១- ផ្តន្ទាទោស៖

ក.លើជនជាប់ចោទឈ្មោះ [redacted] ចាន់នឿន (ដែលមានសាវតាជាតិដូចខាងលើ) កំណត់ដាក់ពន្ធនាគាររយៈពេល ០៦ ប្រាំមួយខែ តែទោសនេះត្រូវព្យួរ។

ខ.លើជនជាប់ចោទឈ្មោះ [redacted] ចន្ទ្រា (ដែលមានសាវតាជាតិដូចខាងលើ) កំណត់ដាក់ពន្ធនាគាររយៈពេល ០៦ ប្រាំមួយខែ តែទោសនេះត្រូវព្យួរ។

ពីបទ៖ **បើកបរដោយធ្វេសប្រហែស មិនប្រុងប្រយ័ត្នបណ្តាល ឱ្យប្អួសអ្នកដល់ទៃ** ព្រឹត្តនៅភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២- បង្គាប់ឱ្យឈ្មោះ [redacted] ចន្ទ្រា សងសំណងជម្ងឺចិត្តចំនួន ១២,000.000 (ដប់ពីរលានរៀល) មកឱ្យឈ្មោះ [redacted] ចាន់នឿន ការទាមទារលើសពីនេះត្រូវច្រានចោល។

៣- សាលក្រមនេះជំនុំជម្រះជាសាធារណៈ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ កំបាំងចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់នឿន និងឈ្មោះ [redacted] ចន្ទ្រា។

**ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។**

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted] | [redacted]

---

បានចម្លងតាមច្បាប់ដើម

ថ្ងៃអង្គារ ៨កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី**

[redacted] | [redacted]